**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០៣២/០៨ របក.អគគ**

## របាយការណ៍ស្តីពី សកម្មភាពការងារប្រចាំខែ កញ្ញា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កញ្ញា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-សំណើសុំចាត់បញ្ជូនមន្ត្រីចំនួន ២រូប ដើម្បីបញ្ចូលក្នុងគម្រោងបេសកកម្មអាទិភាពបន្តនៅទីស្តីការគណៈ រដ្ឋមន្ត្រី

-សំណើសុំបញ្ជូនឈ្មោះមន្ត្រីរាជការនៃអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសសម្រាប់ឆ្នាំ២០០៨

-សំណើសុំជួបពិភាក្សាជាមួយនឹងតំណាងអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨

-សំណើសុំជួបពិភាក្សាជាមួយនឹងក្រសួងមហាផ្ទៃ ដើម្បីស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជា នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨

-សំណើសុំអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចូលរួមជាអធិបតីក្នុងកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា នៅថ្ងៃច័ន្ទ ទី២២ ខែកញ្ញា ឆ្នាំ២០០៨ វេលាម៉ោង ១៤ៈ៣០នាទី

-ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោង សិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា នៅថ្ងៃច័ន្ទ ទី២២ ខែកញ្ញា ឆ្នាំ២០០៨ វេលាម៉ោង ១៤ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី (អតីតរដ្ឋសភាជាតិ)

-សំណើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចូលជួបដើម្បីសុំការណែនាំអនុវត្តលើការរៀបចំព្រឹត្តិបត្រកំណែទម្រង់ច្បាប់ និងតុលាការ។

## ខ. ការងារកំណែទម្រង់

-ចុះជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ុស្មាន់ (Ombudsman) ជាមួយការិយាល័យប្រជាពលរដ្ឋ នៅខេត្តបាត់ដំបង នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៨

-ចុះជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ុស្មាន់ (Ombudsman) ជាមួយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៨

-ចុះជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ុស្មាន់ (Ombudsman) ជាមួយអាជ្ញា ធរដោះស្រាយវិវាទដីធ្លី នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨

-រៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោង សិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា នៅថ្ងៃច័ន្ទ ទី២២ ខែកញ្ញា ឆ្នាំ២០០៨ វេលាម៉ោង ១៤ះ៣០នាទី នៅទីស្តីការក្រសួងយុត្តិធម៌

-ចុះជួបជាមួយតុលាការគំរូ ខេត្តបន្ទាយមានជ័យ ដើម្បីរៀបចំផែនការការងារ។

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ

-ចូលរួមប្រជុំការងារនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រៀបចំកិច្ចប្រជុំការងារកម្ពុជា គណៈកម្មការអឺរ៉ុបលើកទី២ នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៨។

## ២-សន្និដ្ឋាន

ក្នុងខែ កញ្ញា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ ទន្ទឹងនឹងការបន្តសកម្មភាពលើគម្រោងដែលមានស្រាប់ ដូចជាតុលាការគំរូ និងប្រព័ន្ធសូចនាករជាដើម កំពុងតែប្រឹងប្រែងដើម្បីឱ្យចេញជារូបរាងនូវគម្រោងសហប្រតិបត្តិការជាមួយគម្រោង GTZ ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ

-បន្តរៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តធ្វើការទំនាក់ទំនងជាមួយគណៈមេធាវី

-រៀបចំឯកសារសម្រាប់ពិភាក្សាជាមួយ CCJAP

-រៀបចំឯកសារសម្រាប់ប្រជុំ អឧជជ

-រៀបចំឯកសារសម្រាប់ប្រជុំ GDCC។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ហ៊ឹង សុកុល

ស៊ិុយ ម៉ុងលាង